 រាជបណ្ឌិត្យសភាកម្ពុជា

វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម

# «ជំនឿខ្មែរលើ នាងពួន ចៃកាច់ ខ្លាយតាន់»

ដោយ៖ បណ្ឌិត ជា វណ្ណី

ប្រធានផ្នែកជម្មសាស្ត្រនិងចរិយាសាស្ត្រនៃ

វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម








ចៃជ្រូកព្រៃ ភូមិស្វាយ សម័យបុរេប្រវត្តិសាស្ត្រ

ព្រះរាជាណាចក្រកម្ពុជា ឬអាណាចក្រខ្មែរ គឺជាទឹកដីដែលមានវ័យចំណាស់ជាយូរលង់ណាស់មកហើយ ពោលគឺតាំងពីមុន គ.ស. មកម្ល៉េះ នេះបើយោងតាមការធ្វើកំណាយនៅល្អាងស្ពាននិងម្លូព្រៃ ហើយក៏ជាអាណាចក្រដែលពោរពេញទៅវត្ថុស័ក្តិសិទ្ធិនានា និងជំនឿផ្សេងៗផងដែរ។ វត្ថុមានជំនឿនៅលើទឹកដីកម្ពុជានេះ មានតាំងពីយូរ គឺយូរជាងការចូលមកដល់នៃព្រហ្មញ្ញសាសនា និងព្រះ

ពុទ្ធសាសនាទៅទៀត ព្រោះជនជាតិខ្មែរដើមមានជំនឿលើកម្លាំងធម្មជាតិ និងកម្លាំងក្រៅខ្លួន ដែលជាទូទៅ គេគោរពបូជាវត្ថុអរូបដូចជា អាទិទេព ទេវតា អារុក្ខអារក្ស អ្នកតានានា និងវត្ថុសក្តិសិទ្ធិផ្សេងៗ។ គេសង្កេតឃើញមានវត្ថុស័ក្តិសិទ្ធិនិងវត្ថុមានតម្លៃជាច្រើនអនេកដែលទាក់ទងទៅនឹងជំនឿនិងសាសនាជាច្រើន ដែលធ្វើឱ្យប្រទេសជិតខាងខ្លះកោតស្ញប់ស្ញែងផងដែរ ហើយបញ្ហានេះក៏ជាបុព្វហេតុមួយក្នុងចំណោមបុព្វហេតុផ្សេងៗទៀតដែលធ្វើឱ្យប្រទេសជិតខាងយើង តែងតែចិញ្ចឹមចិត្តចង់បានទឹកដីមួយនេះតាំងពីសម័យដើមរហូតមកដល់បច្ចុប្បន្ន។ ក្នុងចំណោមវត្ថុស័ក្តិសិទ្ធិទាំងនោះ មនុស្សតែងតែមានជំនឿនិងនិយាយតៗគ្នាផងដែរអំពី ចៃកាច់ ខ្នាយតាន់ និងនាងពួន ដែលជាវត្ថុស័ក្តិសទ្ធិដ៏កម្រដែលបុគ្គលមួយចំនួននៅក្នុងសង្គមខ្មែរមានជំនឿជាយូរលង់ណាស់មកហើយ។ គេមានជំនឿថា ប្រសិនបើបុគ្គលណាម្នាក់បានកាន់វត្ថុនោះ បុគ្គលនោះនឹងក្លាយជាមនុស្សដ៏អស្ចារ្យខុសពីមនុស្សធម្មតា រហូតដល់គេជឿថា បុគ្គលនោះជាបុគ្គលដែលកាប់មិនមុតដុតមិនឆេះ បាញ់មិនត្រូវ...។ល។ អ្នកដែលនិយមប្រើវត្ថុសក្តិសិទ្ធនេះ ភាគច្រើនជាបុគ្គលដែលមានអំណាច ជាពិសេសគឺ មេទ័ព ទាហ៊ាន អ្នកចំបាំង គ្រូមន្តអាគមជាដើម។ បុព្វហេតុដែលគេយកវត្ថុស័ក្តិសិទ្ធិនេះមកប្រើ គឺដើម្បីយកឈ្នះលើគូសត្រូវទាំងផ្លូវលោក និងទាំងផ្លូវវេងឆ្ងាយ។ ចៃកាច់ ខ្នាយតាន់ និងនាងពួន ត្រូវបានគេយកមកដាក់ជាប់នឹងខ្លួន ដូចជាធ្វើជាបន្តោងខ្សែកជាដើម ហើយភាគច្រើន គឺមនុស្សប្រុសជាអ្នកនិយមប្រើ។ នាពេលបច្ចុប្បន្ននេះ អ្នកប្រើទាំងនោះនៅតែមានជំនឿថា នាងពួន ចៃកាច់ ឬខ្នាយតាន់របស់ជ្រូកព្រៃ គឺជាវត្ថុស័ក្តិសិទ្ធិដែលនាំមកនូវសិរីមង្គល និងសេចក្តីសុខចម្រុងចម្រើន។

**នាងពួន** វត្ថុដែលលាក់ខ្លួនក្នុងដើមឈើណាមួយដោយមិនឱ្យគេរកឃើញ។ នាងពួនមាននៅក្នុងដើមឫស្សី(មានពណ៌ដូចជាផ្លែទទឹមមិនមានពន្លឺខ្លាំងទេ) និងមាននៅក្នុងដើមដំបងយក្សផងដែរ។ បើយោងតាមអដ្ឋកថានៅក្នុងព្រះពុទ្ធសាសនា នាងពួនត្រូវបានចាត់ទុកជាប្រភេទកែវមុក្តា។ កែវមុក្តានេះ បើតាមវចនានុក្រមសម្តេចព្រះសង្ឃរាជ ***ជួន ណាត*** បានពន្យល់ថា *មុត្តា (មុក្តា) ជាឈ្មោះកែវឬត្បូងមានតម្លៃមួយប្រភេទ; ត្បូងដែលកើតអំពីខ្យង គជ់ខ្យង ខ្យងដាំ : កែវមុក្តា។* បើយោងតាមប្រភពពី **មន្តអាគមខ្មែរ** *កែវមុត្តា គឺជារតនៈមួយក្នុងរតនៈទាំង១០ប្រភេទដូចជា កែវមណី កែវពិទូរ្យ ស័ង្ខសិលា កែវប្រពាឡ ប្រាក់ មាស កែវក្រហម (ត្បូងទទឹម) និងកែវមរកត ជាដើម។* ប្រភពដដែលនេះក៏បានឱ្យដឹងទៀតថា កែវមុក្តា ដែលកើតក្នុងដើមឫស្សី (ជនជាតិខ្មែរហៅថា នាងពួនឫស្សី) មានពណ៌ដូចផ្លែទទឹមមិនមានពន្លឺខ្លាំង ហើយដើមឫស្សនោះ រមែងជាដើមឫស្សី ដែលកើតតែក្នុងទីកន្លែងដែលមិនមែនជាលំនៅរបស់មនុស្ស។

នៅក្នុងព្រះពុទ្ធសាសនា តែងមានការសម្តែងអំពីរតនវត្ថុទាំងនោះ ដូច្នេះតើកែវមុក្តា ដែលតែងមានសម្តែងក្នុងព្រះត្រៃបិដក អដ្ឋកថា និងដីកាជាដើមនោះជាអ្វី? នៅក្នុងសមន្តប្បាសាទិកា អដ្ឋកថាព្រះវិន័យបិដក បានបញ្ជាក់ថាកែវមុក្តាកើតឡើង៨ប្រភេទគឺ៖

១.ហយមុត្តា កែវមុក្តាមានសណ្ឋានដូចរូបសេះ

២.គជមុត្តា កែវមុក្តាមានសណ្ឋានដូច រូបដំរី

៣. រថមុត្តា កែវមុក្តាមានសណ្ឋានដូច រូបរថ

៤. អាមលកមុត្តា កែវមុក្តាមានសណ្ឋានដូច ផ្លែកន្ទួតព្រៃ

៥. វលយមុត្តា កែវមុក្តាមានសណ្ឋានដូច កងដៃ

៦. អង្គុលិវេឋកមុត្តា កែវមុក្តាមានសណ្ឋានដូច វង់ចិញ្ចៀន

៧. កកុធផលមុត្តា កែវមុក្តាមានសណ្ឋានដូច ផ្លែថ្វាន់

៨. បាកតិកមុត្តា កែវមុក្តាប្រក្រតី។

នៅក្នុងគម្ពីរសារត្ថទីបនីដីកា ជាដីកាព្រះវិន័យបិដកនៃអដ្ឋកថា សមន្តប្បាសាទិកា បានពន្យល់ថា កែវមុក្តា កើតក្នុងវត្ថុ៨យ៉ាងមានដូចជា៖ ទី១ កើតត្រង់ ក្រពោងដំរី (ចំត្រង់ពកឬប៉ោងខាងលើក្បាលដំរី ) ទី២ កើតក្នុងខ្នាយជ្រូកព្រៃ ទី៣ កើតក្នុងក្បាលពស់ ទី៤ កើតពីអាកាស ទី៥ កើតក្នុងដើមឫស្សី ទី៦ កើតក្នុងក្បាលត្រី ទី៧ កើតក្នុងស័ង្ខ ទី៨ កើតក្នុងខ្យង។

បណ្តាកែវមុក្តាទាំង៨ពួកនោះ កែវមុក្តាដែលកើតក្នុងក្រពោងដំរី មានពណ៌លឿងមិនមានពន្លឺ។ កែវមុក្តាដែលកើតក្នុងខ្នាយជ្រូកព្រៃមានពណ៌ដូចចង្កូមជ្រូកនោះឯង។ កែវមុក្តាដែលកើតពីក្បាលពស់ មានពណ៌ខៀវជាដើម បរិសុទ្ធល្អ រាងមូល។ កែវមុក្តាដែលកើតពីអាកាសមានពន្លឺ រឹងមាំមួនកម្ចាត់ងងឹតក្នុងពេលយប់ និងជាគ្រឿងប្រើប្រាស់របស់ទេវតានោះឯង។ កែវមុក្តាដែលកើតក្នុងដើមឫស្សីមានពណ៌ដូចផ្លែទទឹម មិនមានពន្លឺខ្លាំង និងដើមឫស្សីពួកនោះ រមែងជាដើមឫស្សីដែលកើតតែក្នុងទីកន្លែងដែលមិនមែនជាលំនៅរបស់មនុស្ស។ កែវមុក្តាដែលកើតពីក្បាលត្រី មានពណ៌ដូចខ្នងត្រីក្អែក មូល ស្រាល និងមិនមានពន្លឺ ហើយត្រីពួកនោះ រមែងជាត្រីដែលកើតតែក្នុងកណ្តាលសមុទ្រ។ កែវមុក្តាដែលកើតពីស័ង្ខ មានពណ៌ដូចពោះស័ង្ខ មានខ្នាតប៉ុនផ្លែកោលៈ ហើយមិនមានពន្លឺ។ កែវមុក្តាដែលកើតពីខ្យង ប្រកបដោយសេចក្តីនៃពន្លឺ មានសណ្ឋានផ្សេងៗគ្នា។

បណ្តាកែវមុក្តា ៨យ៉ាង ដោយកំណើតនេះ កែវមុក្តាដែលកើតពី ត្រី ស័ង្ខ និងខ្យង ជារតនៈដែលកើតក្នុងសមុទ្រ។ សូម្បីកែវមុក្តាដែលកើតពីពស់ប្រភេទខ្លះ ក៏ជារតនៈដែលកើតពីសមុទ្រដែរ ហើយខ្លះទៀត មិនមែនជារតនៈដែលកើតក្នុងសមុទ្រទេ ព្រោះហេតុនោះ កែវមុក្តាដែលកើតក្នុងសមុទ្រមានចំនួនច្រើនប្រាកដក្នុងលោក សូម្បីកែវមុក្តាដែលកើតក្នុងសមុទ្រទាំងនោះ ក៏មានកែវមុក្តាដែលកើតពីខ្យង (សម្បូរណ៍) និងកែវមុក្តាដទៃក៏មានក្នុងគ្រាខ្លះ (មិនសម្បូរណ៍)។

នាងពួន ដើមដំបងយក្ស ឬគេតែងតែហៅឈ្មោះម៉្យាងទៀតថា(ដើមជ្រៀវ)

តាមមតិភាគច្រើនដែលគេធ្លាប់ដឹង គេហៅដើមហ្នឹងថាជា ដើមជ្រៀវ តែចំណែកតាមឯកសារ(រុក្ខជាតិ វាជាពពួកដើមដំបងយក្ស)ដែលឈ្មោះជាភាសាអង់គ្លេសហៅថា(cactus ជាអំបូរ [Family Cactaceae.]។ ជំនឿរពីបុរាណរបស់ខ្មែរយើង ខ្លឹមដើមដំបងយក្សប្រើសម្រាប់៖

. ការពារខាងអំពើ អាបធ្មប់ ព្រលឹងខ្មោចព្រាយបិសាច

. ការពារអំពើទុច្ចរិដ្ឋា(ផ្លូវងងឹតនានា)ការពារអំពើ(គោបា ស្នារតេះ)ជាដើម...។ល។

. ការប្រើប្រាស់ខ្លឹមដំបងយក្ស ភាគច្រើនតែងតែយកមកកែច្នៃធ្វើជាគ្រឿងសក្ការៈបូជាមួយចំនួនជាពិសេសធ្វើជាគ្រាប់អង្កាំ(អជ្ជៈ)តែម្តង ។

**ចៃកាច់** បើតាមវចនានុក្រមសម្តេចព្រះសង្ឃរាជ ជួន ណាត បានពន្យល់ថា៖ *ចៃ គឺជាភ្លុកមេដំរី ឬភ្លុកដំរីស្តេរ តូចៗ ខ្លីៗ ទីទៃពីភ្លុកធម្មតា : កាំបិតស្លាដងចៃ។ ចៃកាច់ គឺចៃដែលមេដំរីកាច់ចោលខ្លួនវានៅជាប់នឹងដើមឈើរស់ (ខ្មែរសម័យបុរាណខ្លះ សន្មតថាជារបស់មានតម្លៃ ព្រោះគេជឿថាជារបស់ត្រជាក់ត្រជុំ)*។

**ខ្នាយតាន់** បើតាមវចនានុក្រមសម្តេចព្រះសង្ឃរាជ **ជួន ណាត** បានពន្យល់ថា *ខ្នាយ៖ចង្កូមស្រួចជាគ្រឿងការពាររបស់ជ្រូក* ។ ប៉ុន្តែបច្ចុប្បន្ននេះ ក៏មានការហៅខ្នាយជ្រូកព្រៃនេះថាជា ចៃកាច់ដែរ គឺជាភ្លុករបស់សត្វជ្រូកព្រៃ ដែលមានជីវិតនៅក្នុងព្រៃជ្រៅ។

ជ្រូកព្រៃតែងតែប្រើខ្នាយ(ភ្លុក)ដ៏មុត និងសាហាវរបស់វា ដើម្បីការពារខ្លួន និងសម្លាប់សត្រូវ ហើយគេជឿថា រាល់ព្រលឹងសត្វដែលបានស្លាប់សោយសារជ្រូកព្រៃសម្លាប់ទាំងអស់នោះ បានស្ថិតខាងនៅចុងភ្លុកសត្វជ្រូកព្រៃនោះឯង ទើបត្រូវគេហៅថា ចៃកាច់ គឺខ្នាយនោះឯង។ លុះយូរៗទៅ ពេលដែលភ្លុកនោះដុះវែងវានឹងជ្រុះនៅពេលណាមួយ ដោយសារជ្រូកព្រៃនឹងយកភ្លុកវាទៅត្រដុសនឹងគល់ឈើ។ គេមានជំនឿថា នៅពេលដែលភ្លុកនោះវាជ្រុះកន្លែងណាហើយ បើទោះជាមានភ្លើងឆេះព្រៃយ៉ាងណាក៏ដោយ ប៉ុន្តែកន្លែងដែលមានចៃកាច់ជ្រុះមិនបានឆេះនោះទេ។ រឿងដែលកាន់តែមិនគួរឱ្យជឿមួយទៀតនោះ គឺចៃកាច់នោះវានឹងដុះកាន់តែវែងទៅៗដោយឯកឯង ទោះជាវាស្ថិតនៅក្នុងដៃមនុស្សដែលយកមកថែរក្សាក៏ដោយ។

បើតាមការសង្កេតរបស់អ្នកភូមិដែលរស់នៅតំបន់ព្រៃភ្នំនិងខ្ពង់រាបមួយចំនួនបានឱ្យដឹងថា *ជ្រូកព្រៃនេះមានទម្លាប់រស់នៅជាហ្វូងរបស់វា ហើយនៅក្នុងហ្វូងជ្រូកនីមួយៗ គេឃើញមានមេហ្វូងមួយជាជ្រូកឈ្មោលដែលមិនត្រឹមតែមានមាឌធំ ហើយខ្លាំងជាងគេទេ វាថែមទាំងកាចសាហាវទៀតផង។ នៅក្នុងខណៈពេលដែលមានកូនជ្រូកព្រៃទើបនឹងកើតមក មេហ្វូងជ្រូកព្រៃដ៏កាចសាហាវខ្លាំងតែងតែសម្លាប់នូវរាល់កូនជ្រូកព្រៃឈ្មោលណាដែលវាទទួលស្គាល់ថាមានមហិទ្ធិឫទ្ធិដូចវា ហើយការបំផ្លាញកូនខ្លួនឯងដូច្នេះ គឺបណ្តាលមកពីមេហ្វូងខ្លាចក្រែងកូនឈ្មោលនៅក្នុងហ្វូងនោះនឹងដណ្តើម*

*អំណាចធ្វើជាមេហ្វូងទៅថ្ងៃក្រោយ។ លុះពេលមេហ្វូងនោះវាដឹងថាខ្លួនវាជិតស្លាប់ ទើបវាទុកកូនឈ្មោលណាដែលប្រកបដោយលក្ខណៈសម្បត្តិរឹងមាំ មានដុះខ្នាយវែងជាងគេ ដើម្បីដឹកនាំហ្វូងជ្រូកព្រៃបន្តពីវាតទៅទៀត។ ចំពោះមេហ្វូងជ្រូកព្រៃដែលចាស់ជរាខ្លាំងនោះ វាដើរទៅកេកន្លែងណាស្ងាត់និងមានដើមឈើផង ដើម្បីយកខ្នាយតាន់របស់វាទាំងពីរទៅកាច់បំបាក់ទុកបង្កប់ចោលនៅនឹងដើមឈើនោះ។ គេមានជំនឿថា មហិទ្ធិឫទ្ធិរបស់ខ្នាយតាន់នៅត្រង់ថា បារមី ឬវត្ថុស័ក្តិសិទ្ធិជាពន្លឺនៅលើថ្វាសជ្រូកព្រៃដែលតាមថែរក្សាគាំពារជានិច្ចកាល។ បារមីនេះឯងដែលពិបាកនឹងមាននរណាម្នាក់អាចសម្លាប់វាដោយងាយបានឡើយ។*

ហេតុដូច្នេះហើយ បានប្រជាជនខ្មែរនៅតាមតំបន់ព្រៃភ្នំ និងតំបន់ខ្ពង់រាបមានជំនឿថា អ្នកដែលរើសបានខ្នាយតាន់ជ្រូកព្រៃយកមកពាក់ គឺគេនឹងមានសេចក្តីសុខសិរីសួស្តីជាពុំខាន។ បារមីនៃខ្នាយតាន់នេះនឹងនៅរក្សាការពារមិនឱ្យសត្រូវជិតឆ្ងាយណាមកបៀតបៀន ឬយកឈ្នះលើខ្លួនគេបានឡើយ។

អ្នកមានខ្នាយតាន់ជ្រូកព្រៃតែងតែកាន់ត្រណមមួយចំនួនយ៉ាងខ្ជាប់ខ្ជួន ហើយគួបផ្សំនឹងមន្តអាគមបន្ថែមផងនោះធ្វើឱ្យខ្នាយតាន់ ជ្រូកព្រៃដែលមានបារមីកាន់ស្រាប់ កាន់តែខ្លាំងថែមទៀត។ គេបានចាត់ទុកជំនឿនេះជាទំនៀមទម្លាប់ប្រពៃណីប្រចាំជនជាតិ ហើយគេយល់ថា បារមីខ្នាយតាន់ជ្រូកព្រៃសម្រាប់ជួយការពារសត្វព្រៃដ៏កាចសាហាវផ្សេងៗ ឬអាវុធដូចជាព្រួញ ស្នា កាំភ្លើងជាដើម។ សូមបញ្ជាក់ផងដែរថា ជំនឿលើចែកាច់ ខ្នាយតាន់ជ្រូកព្រៃក៏កើតមានទៅដល់ប្រជាជនខ្មែរភាគតិចដែលរស់នៅតាមច្រករបៀងនៃព្រំដែនខ្មែរ-លាវផងដែរ។ ជនជាតិខ្មែរលើទាំងនេះមានដូចជា ជានជាតិ ទំពូន ព្នង និងស្មៀងជាដើម ដែលភាគច្រើននៃក្រុមរបស់គាត់ គឺគេនិយមពាក់ខ្នាយតាន់ជ្រូកព្រៃជាប្រចាំថ្ងៃតែម្តង។

ដោយសារតែមានជំនឿបែបបនេះហើយ ដែលពេលខ្លះមនុស្សមួយចំនួនក៏បានតាមសម្លាប់ជ្រូកព្រៃនិងសត្វមានជីវិតដទៃទៀត ដើម្បីយកភ្លុករហូតមក ដែលជាបុព្វហេតុធ្វើឱ្យសត្វព្រៃមួយចំនួនធំស្ទើតែបាត់បង់ផុតពូជពីទឹកដីរបស់ខ្មែរយើងទៅហើយនោះ។

មនុស្សដែលបានក្លាយជាម្ចាស់ ចែកាច់ ខ្នាយតាន់ គឺត្រូវមានត្រណមមួយចំនួនដូចជា មិនត្រូវយកចែកាច់ ទៅឆ្លាក់ជារូបផ្សេងៗ ជាពិសេសមិនត្រូវយកទៅឆ្លាក់ជារូបព្រះជាដាច់ខាត បើមិនដូច្នោះទេ វានឹងធ្វើឱ្យក្រុមគ្រួសារមានរឿងក្តៅក្រហាយ កាប់ចាក់ ឈ្លោះប្រកែក រស់នៅមិនបានសេចក្តីសុខមានជំងឺ ធ្លាក់ខ្លួនក្រ និងអាចឈានដល់ការបាត់បង់ជីវិតផងដែរ ហើយបើសិនជាម្ចាស់នោះ ចង់លក់ដូរក៏មិនបានដែរ តែបើត្រូវដោះដូរជារបស់របរដែលមិនមែនជាប្រាក់កាក់ គឺអាចបាន ដោយមានអុចធូបរៀបរាប់ផ្ទេរឱ្យបានត្រឹមត្រូវ។ ក្រៅពីនោះ គេក៏មានជំនឿថា ដើម្បីធ្វើឱ្យចែកាច់ និងខ្នាយតាន់ កាន់តែសក្តិសិទ្ធ និងត្រជាក់ត្រជុំ គឺគេត្រូវយកចែកាច់ និងខ្នាយតាន់ នោះទៅអភិសេកឱ្យបានចំនួន៧វត្ត។

គេអាចសាកល្បងវិធីផ្សេងៗដើម្បីឱ្យដឹងថា ចែកាច់ និងខ្នាយតាន់នោះមានភាពស័ក្តិសិទ្ធិ ឬមិនមាន តាមរយៈការយកចែកាច់ និងខ្នាយតាន់ទៅដោតនឹងបណ្តូលដើមចែកដែលកាប់ហើយ ហើយ

ប្រសិនបើដើមចេកនោះរលួយ មានន័យថាចៃកាច់ និងខ្នាយតាន់នោះសុទ្ធល្អ។ គេក៏អាចសាកល្បង យកកាំភ្លើងទៅបាញ់លើចៃកាច់ ឬខ្នាយតាន់ដែរ បើកាំភ្លើងនោះបាញ់មិនចេញគ្រាប់ មានន័យថា ចៃកាច់ ឬខ្នាយតាន់នោះស័ក្តិសិទ្ធិ។ ម្យ៉ាងវិញទៀត គេអាចសាកល្បងដោយយកខ្សែអំបោះជ្រលក់នឹងប្រេងសាំងដុតឱ្យឆេះ ហើយដាក់នៅលើចៃកាច់ វានឹងរលត់ពេលដែលវាទៅដល់ចៃកាច់ ឬខ្នាយតាន់។ ប៉ុន្តែការធ្វើពិសោធដោយប្រើភ្លើង គឺអាចមានគ្រោះថ្នាក់ដល់អ្នកដុត ដែលអាចបណ្តាលឱ្យអ្នកនោះទៅជាឈឺ មានគ្រោះថ្នាក់ និងរឿងហេតុផ្សេងៗជាដើម។

សរុបសេចក្តីមក ជំនឿលើនាងពួន ចៃកាច់ ខ្នាយតាន់ជ្រូកព្រៃនៃជនជាតិខ្មែរដែលជាវត្ថុសក្តិសិទ្ធិ ជាវត្ថុខ្លាំងពូកែ អាចជួយថែរក្សាមនុស្សឱ្យរួចផុតពីភយន្តរាយផ្សេងៗ ហើយដែលគេជឿថាវត្ថុទាំងនេះបានជួយផ្តល់ឱ្យនូវភាពត្រជាក់ត្រជុំ មិនឱ្យមានអន្តរាយដល់អ្នកថែរក្សា ក្នុងករណេាអ្នកថែរក្សាវត្ថុទាំងនោះ ត្រូវប្រកាន់អំពើល្អ ទើបរបស់ទាំងនេះផ្តល់ផលល្អដល់ខ្លួន អាចឆ្លុះបញ្ចាំងឱ្យឃើញពីទស្សនៈរបស់មនុស្ស ជាពិសេសនៅពេលដែលប្រឈមមុខនឹងគ្រោះកំណាចអ្វីមួយមកពីខាងក្រៅ រមែងតែប្រាថ្នាសេចក្តីសុខសប្បាយ និងសុវត្ថិភាពតែប៉ុណ្ណោះ ហើយជំនឿនេះក៏ជាមែកធាងនៃខឿនវប្បធម៌អរូបីរបស់ជាតិយើងផងដែរ។ បើទោះជាបច្ចុប្បន្ននេះ វិទ្យាសាស្ត្រមានការរីកចម្រើនយ៉ាងខ្លាំងរហូតដល់សតវត្សទី២១នេះក៏ដោយ ក៏ប្រជាពលរដ្ឋកម្ពុជាបាននិងកំពុងរស់នៅជាមួយនឹងជំនឿផ្សេងៗ ដែលមានដូចជាការជឿលើនាងពួន ចៃកាច់ និងខ្នាយតាន់នេះ។ បើតាមចាស់បុរាណ និងឯកសារផ្សេងៗបានឱ្យដឹងថា ភាគច្រើនអ្នកដែលមានខ្នាយតាន់ ឬចៃកាច់ នេះ គឺជាមេទ័ព អ្នកធំមានអំណាច ឬអ្នកស្ថិតនៅសមរភូមិសង្គ្រាម ដើម្បីការពារខ្លួន និងកំចាត់ខ្មាំងសត្រូវ ហើយរហូតមកទល់នឹងពេលបច្ចុប្បន្ននេះ ចៃកាច់ ឬក៏ខ្នាយតាន់ ក៏នៅតែមានឥទ្ធិពលយ៉ាងខ្លាំងក្លាផងដែរ។ បើតាមអ្នកប្រាស្រ័យជីវិតនឹងរបរនេះ បានឱ្យដឹងថា អ្នកដែលទិញរបស់ស័ក្តិសិទ្ធិទាំងនេះ ភាគច្រើនជាមន្ត្រីរាជការធំ។ យើងត្រូវចងចាំថា *ការគោរពជឿលើវត្ថុសក្តិសិទ្ធ ការគោរពជឿលើសាសនា ការគោរពច្បាប់ ការចេះគោរពខ្លួនឯង គោរពឪពុកម្តាយ ចាស់ទុំ និងគោរពអ្នកដទៃ នោះវត្ថុសក្តិសិទ្ធនឹងតាមថែរក្សាយើងជានិច្ច*៕